The Independent Accountability Mechanism for IFC & MIGA

ខែមិថុនា ឆ្នាំ២០២៦

# របាយការណ៍វាយតម្លៃ

## ស្តីពីពាក្យបណ្តឹងទី១៦ ដែលបានទទួលពាក់ព័ន្ធនឹងការវិនិយោគរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) នៅក្នុងធនាគារ ហត្ថា ម.ក នៅកម្ពុជា

លេខគម្រោង IFC៖ ៤៤៧៤២

## អំពី CAO

ការិយាល័យទីប្រឹក្សាអនុលោមភាព (ហៅកាត់ថា CAO) គឺជាយន្តការគណនេយ្យភាពឯករាជ្យរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និង ទីភ្នាក់ងារធានាការវិនិយោគពហុភាគី (MIGA) ដែលជាសមាជិកនៃក្រុមធនាគារពិភពលោក។ យើងធ្វើការដើម្បីសម្របសម្រួលការដោះស្រាយពាក្យបណ្តឹងពីប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោងរបស់ IFC និង MIGA ប្រកបដោយភាពយុត្តិធម៌ សត្យានុម័ត និងក្នុងលក្ខណៈស្ថាបនា ពង្រឹងលទ្ធផលផ្នែកបរិស្ថាន និងសង្គមរបស់គម្រោង និងជំរុញគណនេយ្យភាពសាធារណៈ និងការសិក្សារៀនសូត្រនៅ IFC និង MIGA។

CAO គឺជាការិយាល័យឯករាជ្យ ដែលរាយការណ៍ដោយផ្ទាល់ទៅក្រុមប្រឹក្សាភិបាលប្រតិបត្តិរបស់ IFC និង MIGA។ សម្រាប់ព័ត៌មានបន្ថែម សូមមើល www.cao-ombudsman.org/about-us.

# បញ្ជីពាក្យកាត់

CAO : ការិយាល័យទីប្រឹក្សាអនុលោមភាព ( Office of the Compliance Advisor Ombudsman )

FCPC : មជ្ឈមណ្ឌលការពារអតិថិជនហិរញ្ញវត្ថុ ( Financial Consumer Protection Center )

HTB : ធនាគារ ហត្ថា ម.ក ( Hattha Bank Plc. )

IFC : សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ( International Finance Corporation )

MIGA : ទីភ្នាក់ងារធានាការវិនិយោគពហុភាគី ( Multilateral Investment Guarantee Agency )

# ១. សង្ខេប

នៅខែកក្កដា ឆ្នាំ២០២៥ អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស ហៅកាត់ថា លីកាដូ (LICADHO) បានដាក់ពាក្យបណ្ដឹងតំណាងឱ្យដើមបណ្ដឹង ទៅកាន់ការិយាល័យទីប្រឹក្សាអនុលោមភាព (CAO) ដោយចោទប្រកាន់ពីការអនុវត្តការផ្ដល់កម្ចីប្រកបដោយគ្រោះថ្នាក់ នៅក្នុងវិស័យហិរញ្ញវត្ថុកម្ពុជា។ ពាក្យបណ្ដឹងនេះទាក់ទងនឹងធនាគារ ហត្ថា ម.ក (HTB) ដែលជាអតិថិជនរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដែល IFC មានការវិនិយោគដោយផ្ទាល់។

បន្ទាប់ពី CAO បានបង្កើតទំនាក់ទំនងដំបូងជាមួយដើមបណ្ដឹង និងបង្ហាញជម្រើសដែលមានសម្រាប់ការដោះស្រាយបញ្ហាដែលបានលើកឡើង ដើមបណ្ដឹងបានជ្រើសរើសទាក់ទងមជ្ឈមណ្ឌលការពារអតិថិជនហិរញ្ញវត្ថុ (FCPC) នៅកម្ពុជា ដើម្បីស្វែងរកលទ្ធភាពពន្លឿនដំណោះស្រាយ និងបានដាក់ពាក្យបណ្ដឹងទៅ FCPC នៅខែមករា ឆ្នាំ២០២៦។ នៅខែមីនា ឆ្នាំ២០២៦ ដើមបណ្ដឹងបានជម្រាបជូន CAO ថា បញ្ហាទាំងនេះមិនត្រូវបានដោះស្រាយតាមរយៈ FCPC ឡើយ។ បន្ទាប់មក CAO បានទទួលស្គាល់ពាក្យបណ្ដឹងនេះជាផ្លូវការ ដោយកំណត់ថាពាក្យបណ្ដឹងនេះបានបំពេញតាមលក្ខណៈវិនិច្ឆ័យនៃភាពទទួលយកបាន (eligibility criteria) និងបានចាប់ផ្ដើមធ្វើការវាយតម្លៃលើករណីនេះ នៅចុងខែនោះ។ ដើមបណ្ដឹងបានអះអាងថា គាត់រងផលប៉ះពាល់អវិជ្ជមានដោយសារការផ្ដល់ឥណទាន និងការអនុវត្តការប្រមូលបំណុលរបស់ធនាគារ ហត្ថា រួមទាំងការបដិសេធរបស់ធនាគារមិនរៀបចំឥណទានឡើងវិញ ស្របតាមស្ថានភាពហិរញ្ញវត្ថុរបស់គាត់ ការចោទប្រកាន់អំពីការគំរាមកំហែង និងការបំភិតបំភ័យពីសំណាក់មន្ត្រីឥណទាន និងការដាក់សម្ពាធឱ្យលក់ដី ដើម្បីសងបំណុលដែលជំពាក់។ ក្នុងអំឡុងពេលនៃការវាយតម្លៃរបស់ CAO ដើមបណ្ដឹង និងធនាគារ ហត្ថា បានយល់ព្រមចូលរួមដោយផ្ទាល់ ដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើង។ នៅខែឧសភា ឆ្នាំ២០២៦ CAO បានទទួលព័ត៌មានពីភាគីនានាថា បញ្ហានៅក្នុងពាក្យបណ្ដឹងត្រូវបានដោះស្រាយ។ អនុលោមតាមគោលនយោបាយ CAO (កថាខណ្ឌ ៥៥)[1] CAO បានបញ្ចប់ដំណើរការវាយតម្លៃ និងបានបិទសំណុំរឿងនេះ។

របាយការណ៍វាយតម្លៃនេះ បង្ហាញជារួមពីដំណើរការវាយតម្លៃ រួមទាំងការពិពណ៌នាអំពីគម្រោង ពាក្យបណ្ដឹង វិធីសាស្ត្រវាយតម្លៃ និងទស្សនៈរបស់ភាគីនានា។

---

[1] CAO (ការិយាល័យទីប្រឹក្សាអនុលោមភាព)។ ២០២១។ *គោលនយោបាយយន្តការគណនេយ្យភាពឯករាជ្យ (CAO) របស់ IFC និង MIGA*។ https://www.cao-ombudsman.org/policies-guidelines.

# ២. សាវតារ

## ២.១ គម្រោង

ធនាគារ ហត្ថា ម.ក (HTB) គឺជាធនាគារពាណិជ្ជដែលទទួលបានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្មកម្ពុជា នៅខែសីហា ឆ្នាំ២០២០។[2] ដើមឡើយ ស្ថាប័ននេះត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៤ ដោយអង្គការកាណាដាមួយឈ្មោះ OCSD/OXFAM–Quebec ដើម្បីផ្តល់ប្រាក់កម្ចីខ្នាតតូចដល់ឃុំនៅតំបន់ជនបទក្នុងខេត្តពោធិ៍សាត់។ នៅឆ្នាំ២០០១ ធនាគារ ហត្ថា ត្រូវបានចុះបញ្ជីជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត (ហត្ថាកសិករ លីមីតធីត) ដោយផ្តោតលើការអភិវឌ្ឍ និងឥណទានសម្រាប់សហគ្រាសខ្នាតតូចបំផុត និងតូច។

ធនាគារ ហត្ថា គឺជាអតិថិជនរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) តាំងពីឆ្នាំ២០១៥ និងទទួលបានការវិនិយោគពី IFC ចំនួនប្រាំបីលើក ក្នុងទម្រង់ជាឥណទានដែលមានគោលបំណងពង្រីកផលប័ត្រឥណទានសម្រាប់សហគ្រាសធុនមីក្រូ តូច និងមធ្យម របស់ធនាគារ ហត្ថា។[3] កន្លងមក IFC ធ្លាប់មានការជាប់ពាក់ព័ន្ធហិរញ្ញវត្ថុដោយប្រយោលជាមួយធនាគារ ហត្ថា តាមរយៈការវិនិយោគរបស់ខ្លួននៅក្នុងកម្មវិធីលើកកម្ពស់មីក្រូហិរញ្ញវត្ថុ (Microfinance Enhancement Facility)។[4]

គិតត្រឹមខែកក្កដា ឆ្នាំ២០២៥ IFC មានគម្រោងសកម្មតែមួយគត់ជាមួយធនាគារ ហត្ថា (គម្រោងលេខ ៤៤៧៤២) ដែលជាឥណទានមានការចូលរួមពីស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត (syndicated loan) រយៈពេល ៧ឆ្នាំ មានគុណវុឌ្ឍិជាមូលធនថ្នាក់ទី២ ក្នុងទំហំទឹកប្រាក់រហូតដល់ ៤០លានដុល្លារអាមេរិក ក្នុងនោះមានការវិនិយោគពីគណនីផ្ទាល់របស់ IFC រហូតដល់ ១០លានដុល្លារអាមេរិក និងការកៀរគរធនធានរហូតដល់ ៣០លានដុល្លារអាមេរិក។ គិតត្រឹមខែមិថុនា ឆ្នាំ២០២៦ ទឹកប្រាក់ឥណទានដែលមិនទាន់ទូទាត់សរុបមានចំនួន ២៤លានដុល្លារអាមេរិក ដែលក្នុងនោះ ៦លានដុល្លារអាមេរិក គឺជាការវិនិយោគពីគណនីផ្ទាល់របស់ IFC និង ១៨ លានដុល្លារអាមេរិក ត្រូវបានកៀរគរពីប្រភពផ្សេងៗ។គោលបំណងនៃឥណទាននេះ គឺដើម្បីពង្រឹងភាពធន់របស់ធនាគារ ហត្ថា ចំពោះមុខការរាតត្បាតនៃជំងឺកូវីដ-១៩ និងដើម្បីគាំទ្រយុទ្ធសាស្ត្ររយៈពេលវែងរបស់ធនាគារក្នុងការបង្កើនការផ្តល់ហិរញ្ញប្បទានជាចម្បងដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម រួមទាំងសហគ្រាសដែលជាកម្មសិទ្ធិរបស់ស្ត្រី និង

---

2 សម្រាប់ព័ត៌មានបន្ថែមអំពីធនាគារ ហត្ថា សូមមើល https://www.hatthabank.com/page/bank-profile.

3 លេខគម្រោង IFC៖ ៣៩១៦៧, ៤៤២១១, ៤៥៥៣៥ និង ៤៤៧៤២។

4 កម្មវិធីលើកកម្ពស់មីក្រូហិរញ្ញវត្ថុ (Microfinance Enhancement Facility) ដើមឡើយបានបង្ហាញខ្លួននៅលើឯកសារផ្សព្វផ្សាយរបស់ IFC ជាកម្មវិធីសាច់ប្រាក់ងាយស្រួលមីក្រូហិរញ្ញវត្ថុ (Microfinance Liquidity Facility)។ ក្រោយមកវាត្រូវបានប្តូរឈ្មោះជាកម្មវិធីលើកកម្ពស់មីក្រូហិរញ្ញវត្ថុ ហើយបន្ទាប់មកត្រូវបានប្តូរឈ្មោះម្តងទៀតជា មូលនិធិឆ្លាតវៃយេនឌ័រសកល (Global Gender-Smart Fund)។ សូមមើលឯកសារផ្សព្វផ្សាយរបស់ IFC នៅ https://disclosures.ifc.org/enterprise-search-results-home/27827

ដើម្បីពង្រឹងភាពគ្រប់គ្រាន់នៃដើមទុនរបស់ធនាគារ ហត្ថា។ គម្រោងនេះត្រូវបានអនុម័តនៅឆ្នាំ២០២១ និងបានចាត់ថ្នាក់ផ្នែកបរិស្ថាន និងសង្គមជាប្រភេទ FI-2 (សក្តានុពលបង្កផលប៉ះពាល់អវិជ្ជមានមានកម្រិត) យោងតាមនីតិវិធីត្រួតពិនិត្យបរិស្ថាន និងសង្គមរបស់ IFC។

## ២.២ ពាក្យបណ្ដឹង

នៅខែកក្កដា ឆ្នាំ២០២៥ ការិយាល័យទីប្រឹក្សាអនុលោមភាព (CAO) បានទទួលពាក្យបណ្ដឹងមួយទាក់ទងនឹងការវិនិយោគដែលបន្តនៅមានរបស់ IFC នៅក្នុងធនាគារ ហត្ថា នៅកម្ពុជា។ ការដាក់ពាក្យបណ្ដឹងនេះត្រូវបានសម្របសម្រួលដោយអង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) ដែលកំពុងដើរតួជាតំណាងរបស់ដើមបណ្ដឹងនៅក្នុងដំណើរការនេះផងដែរ។ ពាក្យបណ្ដឹងនេះលើកឡើងពីក្ដីបារម្ភទាក់ទងនឹងការខិតខំប្រឹងប្រែងដែលមិនទទួលបានជោគជ័យក្នុងការរៀបចំឥណទានឡើងវិញ ការបង្ខិតបង្ខំឱ្យលក់ដីនៅក្រៅនីតិវិធីរឹបអូសទ្រព្យសម្បត្តិផ្លូវការ និងការចោទប្រកាន់អំពីការគំរាមកំហែង និងការបំភិតបំភ័យ ពីសំណាក់មន្ត្រីឥណទាន។

បន្ទាប់ពី CAO បានបង្កើតទំនាក់ទំនងដំបូងជាមួយដើមបណ្ដឹងក្នុងខែមករា ឆ្នាំ២០២៦ គាត់បានទាក់ទងមជ្ឈមណ្ឌលការពារអតិថិជនហិរញ្ញវត្ថុ (FCPC) ដើម្បីមើលថាតើស្ថាប័ននេះអាចពន្លឿនករណីរបស់គាត់ដែរឬទេ។ គាត់បានដាក់ពាក្យបណ្ដឹងទៅកាន់ FCPC ក្នុងខែមករា ប៉ុន្តែត្រឹមខែមីនា ឆ្នាំ២០២៦ បានជម្រាបជូន CAO ថាបញ្ហារបស់គាត់មិនត្រូវបានដោះស្រាយតាមរយៈ FCPC នោះទេ ហើយថាគាត់មានចំណាប់អារម្មណ៍ក្នុងការបន្តដំណើរការឡើងវិញជាមួយ CAO។ CAO បានទទួលស្គាល់ពាក្យបណ្ដឹងជាផ្លូវការ ហើយនៅក្នុងខែមេសា ឆ្នាំ២០២៦ បានកំណត់ថាពាក្យបណ្ដឹងនេះបានបំពេញតាមលក្ខណៈវិនិច្ឆ័យនៃភាពទទួលយកបាន (eligibility criteria) និងបានចាប់ផ្ដើមធ្វើការវាយតម្លៃ។

# ៣. គោលបំណង និងវិធីសាស្ត្រនៃការវាយតម្លៃ

## ៣.១ គោលបំណងនៃការវាយតម្លៃ

ដំណើរការវាយតម្លៃរបស់ CAO នេះមានគោលបំណងស្វែងយល់ឱ្យបានស៊ីជម្រៅអំពីបញ្ហា និងកង្វល់ដែលបានលើកឡើងដោយដើមបណ្ដឹង ប្រមូលព័ត៌មានស្ដីពីទស្សនៈរបស់ភាគីពាក់ព័ន្ធនានា និងកំណត់ថាតើដើមបណ្ដឹង និងអតិថិជនរបស់ IFC ចង់បន្តដំណើរការដោះស្រាយវិវាទក្រោមការសម្របសម្រួលដោយ CAO ឬថាតើករណីនេះគួរតែចាត់ចែងដោយមុខងារអនុលោមភាពរបស់ CAO ដើម្បីធ្វើការពិនិត្យវាយតម្លៃលើស្តង់ដារសមិទ្ធកម្មរបស់ IFC។ (សូមមើលឧបសម្ព័ន្ធ ក សម្រាប់ការពិពណ៌នាអំពីដំណើរការដោះស្រាយពាក្យបណ្ដឹងរបស់ CAO។)

ដំណើរការវាយតម្លៃរបស់ CAO មិនធ្វើការវិនិច្ឆ័យលើអង្គហេតុនៃពាក្យបណ្ដឹងឡើយ។ ផ្ទុយទៅវិញ គោលដៅនៃដំណើរការនេះ គឺដើម្បីស្វែងយល់ពីទស្សនៈរបស់ភាគីនានា និងជួយឱ្យអ្នកពាក់ព័ន្ធធ្វើការសម្រេចចិត្តផ្អែកលើព័ត៌មានត្រឹមត្រូវ អំពីរបៀបដោះស្រាយបញ្ហាដែលបានលើកឡើង។

## ៣.២ វិធីសាស្ត្រវាយតម្លៃ

រូបភាពទី ១ បង្ហាញពីអភិក្រម និងវិធីសាស្ត្រ ដែលត្រូវបានអនុវត្តនៅក្នុងដំណើរការវាយតម្លៃរបស់ CAO។

**រូបភាពទី ១. ដំណើរការវាយតម្លៃរបស់ CAO**

តាមរយៈដំណើរការវាយតម្លៃ CAO មានគោលបំណងស្វែងយល់ឱ្យបានច្បាស់លាស់បន្ថែមទៀត អំពីបញ្ហានានា និងកំណត់ថាតើភាគីនានាមានបំណងដោះស្រាយពាក្យបណ្ដឹង តាមរយៈដំណើរការដោះស្រាយវិវាទ ឬដំណើរការអនុលោមភាព។ ការវាយតម្លៃនេះ រួមមាន៖

- ការពិនិត្យលើឯកសារគម្រោងរបស់ IFC និងឯកសារពាក់ព័ន្ធផ្សេងទៀត
- កិច្ចប្រជុំតាមប្រព័ន្ធអនឡាញជាមួយក្រុមការងារគម្រោង IFC និងក្រុមការងារទទួលបន្ទុកការចូលរួមរបស់ភាគីពាក់ព័ន្ធ និងការដោះស្រាយបណ្ដឹងរបស់ IFC
- កិច្ចប្រជុំតាមប្រព័ន្ធអនឡាញជាមួយធនាគារ ហត្ថា
- ការទំនាក់ទំនងតាមទូរស័ព្ទជាមួយដើមបណ្ដឹង

របាយការណ៍វាយតម្លៃ / របាយការណ៍សេចក្ដីសន្និដ្ឋាន

ការវាយតម្លៃនេះ ត្រូវបានធ្វើឡើងដោយក្រុមការងារវាយតម្លៃរបស់ CAO ដោយមានការគាំទ្រពីអ្នកសម្របសម្រួល (Mediators) ចំនួនពីររូប និងអ្នកបកប្រែភាសាក្នុងស្រុកម្នាក់ដែលមានមូលដ្ឋាននៅកម្ពុជា ដែលបានជួយក្នុងការបកប្រែភាសាខ្មែរ និងផ្ទាល់មាត់ ទៅតាមការចាំបាច់។ ការប្រាស្រ័យទាក់ទងជាមួយភាគីនានា ត្រូវបានធ្វើឡើង តាមរយៈកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ និងការហៅទូរស័ព្ទ។

## ៤. ទស្សនៈរបស់ដើមបណ្តឹង

ដើមបណ្តឹងបានលើកឡើងថាជួបការលំបាកផ្នែកហិរញ្ញវត្ថុ និងផលប៉ះពាល់អវិជ្ជមានមកលើសង្គម ដែលពាក់ព័ន្ធនឹងការ ផ្តល់ឥណទានមីក្រូហិរញ្ញវត្ថុ និងការអនុវត្តការប្រមូលបំណុលរបស់ធនាគារ ហត្ថា (HTB) ជាពិសេសកម្ចីដែលគាត់ទទួលបានពីធនាគារ ហត្ថា ក្នុងឆ្នាំ២០២២។ ក្តីបារម្ភដែលបានរៀបរាប់ដោយដើមបណ្តឹង ត្រូវបានសង្ខេបដូចខាងក្រោមៈ

**ការខិតខំប្រឹងប្រែងដែលមិនទទួលបានជោគជ័យក្នុងការរៀបចំឥណទានឡើងវិញ៖** ដើមបណ្តឹងទទួលបានកម្ចីពីធនាគារ ហត្ថា ដើម្បីទិញដីទុកជាការវិនិយោគ ដោយប្រើប្រាស់ផ្ទះគ្រួសាររបស់គាត់ជាទ្រព្យធានា និងផ្តល់អ្នកធានាបន្ថែម ដើម្បីទទួលបានកម្ចីនេះ។ ប្រាក់កម្ចីត្រូវបានប្រើប្រាស់ ដើម្បីវិនិយោគលើដីចំនួនពីរឡូត៍ តាមរយៈក្រុមហ៊ុនវិនិយោគមួយ ដែលអះអាងថានឹងទទួលបានប្រាក់ចំណេញប្រចាំខែ។ ប្រាក់ចំណេញរំពឹងទុកទាំងនេះ មានគោលបំណងបម្រើជាប្រភពចំណូលគ្រួសារផង និងជាមធ្យោបាយសម្រាប់បំពេញកាតព្វកិច្ចសងប្រាក់កម្ចីផង។ ទោះជាយ៉ាងណាក៏ដោយ ការពាក់ព័ន្ធរបស់ដើមបណ្តឹងជាមួយក្រុមហ៊ុនវិនិយោគនោះ បានបណ្តាលឱ្យមានការខាតបង់ហិរញ្ញវត្ថុ ដោយសារការចោទប្រកាន់ថាមានការបោកប្រាស់ ដែលបានធ្វើឱ្យប៉ះពាល់ដល់ស្ថិរភាពហិរញ្ញវត្ថុរបស់គ្រួសារ។ ដូច្នេះ ដើមបណ្តឹងមិនអាចបង់សងប្រាក់កម្ចីតាមកាលវិភាគបានទេ។ គាត់បាននិយាយថា គាត់បានជូនដំណឹងដល់ធនាគារ ហត្ថា អំពីស្ថានភាពហិរញ្ញវត្ថុរបស់គាត់ដែលបានធ្លាក់ចុះ ហើយបានស្នើសុំរៀបចំឥណទានឡើងវិញ ដើម្បីសម្របសម្រួលកាតព្វកិច្ចសងប្រាក់ ស្របតាមលទ្ធភាពហិរញ្ញវត្ថុរបស់គាត់។ គាត់បានស្នើសុំជាពិសេសនូវការកែសម្រួលកាលវិភាគសងប្រាក់ រួមទាំងការកាត់បន្ថយប្រាក់បង់ប្រចាំខែ និងការពន្យាររយៈពេលកម្ចី ប៉ុន្តែបានអះអាងថា ធនាគារ ហត្ថា មិនបានអនុម័តលើសំណើរបស់គាត់ឡើយ។

**ការដាក់សម្ពាធឱ្យលក់ដីនៅក្រៅនីតិវិធីរឹបអូសទ្រព្យសម្បត្តិផ្លូវការ៖** ដើមបណ្តឹងបានចោទប្រកាន់ថា មន្ត្រីឥណទានបានដាក់សម្ពាធមកលើគាត់ ដោយស្នើឱ្យគាត់ខ្ចីប្រាក់ក្រៅប្រព័ន្ធបន្ថែម ឬលក់ដីរបស់គាត់ ដើម្បីទូទាត់បំណុលដែលជំពាក់។ គាត់បានអះអាងថា គាត់ និងអ្នកធានារបស់គាត់ ត្រូវបានស្នើសុំឱ្យចូលរួមកិច្ចប្រជុំជាច្រើនលើកជាមួយមន្ត្រីឥណទានធនាគារពាក់ព័ន្ធនឹងកម្ចីនេះ ដែលក្នុងអំឡុងពេលនោះ ធនាគារ ហត្ថា បានណែនាំពួកគេអំពីផលវិបាកដែលអាចកើតមាន ប្រសិនបើនៅតែបន្តខកខានមិនបានបង់ប្រាក់ រួមទាំងចំណាត់ការផ្លូវច្បាប់ ការអនុវត្តការរឹបអូសទ្រព្យធានា និងលទ្ធភាពដែលអ្នកធានាអាចត្រូវទទួលខុសត្រូវលើបំណុលដែលជំពាក់។

**ការគំរាមកំហែង និងការបំភិតបំភ័យដោយមន្ត្រីឥណទាន៖** ដើមបណ្តឹងបានអះអាងថា មន្ត្រីឥណទានរបស់ធនាគារ ហត្ថា បានព្រមានគាត់ថា ចំណាត់ការផ្លូវច្បាប់ណាមួយអាចបណ្តាលឱ្យមានបំណុលបន្ថែម រួមទាំងថ្លៃសេវាផ្លូវច្បាប់ និងថ្លៃចំណាយពាក់ព័ន្ធនឹងតុលាការ។ បន្ទាប់មកនៅឆ្នាំ២០២៤ បញ្ហានេះត្រូវបានបញ្ជូនទៅតុលាការ។ ទោះបីជាមានការលំបាកផ្នែកហិរញ្ញវត្ថុក៏ដោយ ដើមបណ្តឹងបានអះអាងថា គាត់នៅតែបន្តបង់ប្រាក់មួយផ្នែកតូចៗ និងបានស្វែងរកការចរចាជាច្រើនដង ដើម្បីកែសម្រួលលក្ខខណ្ឌសងប្រាក់ ដែលអនុញ្ញាតឱ្យគាត់បន្តដោះស្រាយ

បំណុល។ គាត់បាននិយាយថា មន្ត្រីឥណទានរបស់ធនាគារ ហត្ថា មិនយល់ព្រមរៀបចំឥណទានរបស់គាត់ឡើងវិញទេ ហើយក៏មិនទទួលយកផែនការសងប្រាក់ដែលគាត់បានស្នើឡើងនោះដែរ។

នៅពេលដែលដើមបណ្តឹងដាក់ពាក្យបណ្តឹងទៅកាន់ CAO គាត់បានស្នើសុំរក្សាព័ត៌មានផ្ទាល់ខ្លួនរបស់គាត់ជាការសម្ងាត់ ប៉ុន្តែគាត់បានយល់ព្រមចែករំលែកព័ត៌មានរបស់គាត់ជាមួយធនាគារ ហត្ថា សម្រាប់ការចរចាបន្ថែម។

បន្ទាប់ពីដាក់ពាក្យបណ្តឹងរបស់គាត់ទៅកាន់ CAO ដើមបណ្តឹងបានជ្រើសរើសបន្តការសម្រុះសម្រួលតាមរយៈមជ្ឈមណ្ឌលការពារអតិថិជនហិរញ្ញវត្ថុ (FCPC) នៅកម្ពុជា ក្នុងគោលបំណងចរចាអំពីការរៀបចំការសងប្រាក់ជាជម្រើសផ្សេងជាមួយធនាគារ។ ទោះបីជាភាគីទាំងពីរបានចូលរួមក្នុងដំណើរការសម្រុះសម្រួលតាមរយៈ FCPC ក៏ដោយ ក៏ពួកគេមិនអាចឈានដល់ដំណោះស្រាយដែលអាចទទួលយកបានទៅវិញទៅមកឡើយ។ ជាលទ្ធផល ដើមបណ្តឹងបានធ្វើឱ្យពាក្យបណ្តឹងរបស់គាត់មានសុពលភាពឡើងវិញនៅចំពោះមុខ CAO។

## ៥. ទស្សនៈរបស់អតិថិជន IFC

ទស្សនៈរបស់ធនាគារ ហត្ថា ដែលជាអតិថិជនរបស់ IFC ចំពោះបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង ត្រូវបានសង្ខេបដូចខាងក្រោម៖

**ការខិតខំប្រឹងប្រែងដែលមិនទទួលបានជោគជ័យក្នុងការរៀបចំឥណទានឡើងវិញ៖** ជាការឆ្លើយតបទៅនឹងក្តីបារម្ភដែលត្រូវបានចោទប្រកាន់នៅក្នុងពាក្យបណ្តឹង ធនាគារ ហត្ថា បានថ្លែងថា ខ្លួនបានផ្តល់ការគាំទ្រផ្នែករៀបចំឥណទានឡើងវិញដល់អ្នកខ្ចីប្រាក់ជាច្រើន ជាពិសេសអ្នកដែលមានចំនួនកម្ចីតូចតាច ដែលជួបការលំបាកផ្នែកហិរញ្ញវត្ថុ ដោយផ្អែកលើការវាយតម្លៃអំពីលទ្ធភាពសងប្រាក់ និងកាលៈទេសៈបុគ្គលរបស់ពួកគេ។ ធនាគារក៏បានបង្ហាញផងដែរថា ការរៀបចំឡើងវិញអាចរួមបញ្ចូលទាំងការកែសម្រួលលក្ខខណ្ឌសងប្រាក់ ហើយថាការប្រាក់ដែលកើតឡើង មិនត្រូវបានបូកបញ្ចូលទៅក្នុងសមតុល្យប្រាក់ដើមឡើយ។ ធនាគារបានអះអាងថា អ្នកខ្ចីប្រាក់ដែលប្រឈមនឹងបញ្ហាក្នុងការសងប្រាក់ ត្រូវបានលើកទឹកចិត្តឱ្យទាក់ទងសាខាក្នុងតំបន់របស់ពួកគេ ដើម្បីស្វែងរកដម្រើសដែលស្របតាមស្ថានភាពហិរញ្ញវត្ថុរបស់ពួកគេ។ ធនាគារបានបង្ហាញពីឆន្ទៈក្នុងការសហការដោយផ្ទាល់ជាមួយដើមបណ្តឹង ដើម្បីស្វែងរកមធ្យោបាយដោះស្រាយបញ្ហាទាំងនេះ។

**ការដាក់សម្ពាធឱ្យលក់ដីនៅក្រៅនីតិវិធីរឹបអូសទ្រព្យសម្បត្តិផ្លូវការ៖** យោងតាមធនាគារ ហត្ថា នៅពេលដែលអ្នកខ្ចីប្រាក់ជួបការលំបាកក្នុងការសងប្រាក់ មន្ត្រីឥណទានបានទាក់ទងជាមួយពួកគេ ដើម្បីពន្យល់ពីលក្ខខណ្ឌនៃកិច្ចព្រមព្រៀងកម្ចីរបស់ពួកគេ រួមទាំងកាតព្វកិច្ចតាមកិច្ចសន្យារបស់អ្នកខ្ចី និងអ្នកធានា ព្រមទាំងចំណាត់ការទាក់ទងនឹងការមិនសងប្រាក់កម្ចី។ ការពិភាក្សាទាំងនេះមានគោលបំណងធានាថា អ្នកខ្ចីប្រាក់យល់ច្បាស់អំពីសិទ្ធិនិងកាតព្វកិច្ចរបស់ពួកគេ ក្រោមកិច្ចព្រមព្រៀងកម្ចី និងនីតិវិធីច្បាប់ដែលអាចអនុវត្តបាន។ ធនាគារ ហត្ថា បានពន្យល់បន្ថែមថា ក្នុងករណីមានការយឺតយ៉ាវអូសបន្លាយ មន្ត្រីឥណទានអាចពិភាក្សាអំពីជម្រើសផ្សេងៗដែលមានសម្រាប់អ្នកខ្ចីប្រាក់ ដើម្បីបំពេញកាតព្វកិច្ចសងប្រាក់របស់ពួកគេ រួមទាំងការរៀបចំឥណទានឡើងវិញផងដែរ នៅពេលដែលសមស្រប។ ធនាគារ ហត្ថា បានសង្កត់ធ្ងន់ថា រាល់ការសម្រេចចិត្តទាក់ទងនឹងការលក់ទ្រព្យសម្បត្តិ ឬការទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុពីសមាជិកគ្រួសារ ឬភាគីទីបី គឺស្ថិតនៅលើការសម្រេចចិត្តទាំងស្រុងរបស់អ្នកខ្ចីប្រាក់។

**ការគំរាមកំហែង និងការបំភិតបំភ័យដោយមន្ត្រីឥណទាន៖** ធនាគារ ហត្ថា បានអះអាងថា មន្ត្រីឥណទានរបស់ខ្លួនទទួលបានការបណ្តុះបណ្តាលជាប្រចាំ ស្តីពីការអនុវត្តការផ្តល់កម្ចីប្រកបដោយការទទួលខុសត្រូវ ការប្រាស្រ័យទាក់ទងជាមួយអតិថិជន និងការអនុលោមតាមគោលនយោបាយ និងនីតិវិធីរបស់ធនាគារ។ ធនាគាររំពឹងថា បុគ្គលិកទាំងអស់នឹងប្រកាន់ខ្ជាប់នូវភាពជាអ្នកអាជីព និងមានការគោរព នៅពេលទំនាក់ទំនងជាមួយអ្នកខ្ចីប្រាក់ ហើយត្រូវអនុវត្តតាមគោលការណ៍ដែលបានបង្កើតឡើង នៅពេលគ្រប់គ្រងគណនីដែលយឺតយ៉ាវក្នុងការសងប្រាក់។

## ៦. សេចក្តីសន្និដ្ឋាន និងជំហានបន្ទាប់

ក្នុងអំឡុងពេលដំណើរការវាយតម្លៃរបស់ CAO ធនាគារ ហត្ថា បានផ្តល់ការសហការដោយផ្ទាល់ជាមួយដើមបណ្តឹង ដើម្បីព្យាយាមដោះស្រាយបញ្ហានៅក្នុងពាក្យបណ្តឹង ដោយអនុលោមតាមគោលនយោបាយ CAO កថាខណ្ឌ ៥៥។[5] ដើមបណ្តឹងបានយល់ព្រមចំពោះសំណើនេះ។ យោងតាមដើមបណ្តឹង បន្ទាប់មក ភាគីទាំងពីរបានឈានដល់កិច្ចព្រមព្រៀងមួយ ដែលរួមមានការកាត់បន្ថយសមតុល្យប្រាក់ដើមដែលជំពាក់ ដោយចំនួនដែលបានព្រមព្រៀងគ្នាត្រូវបង់ឱ្យបានពេញលេញក្នុងរយៈពេលប្រាំមួយខែ។ ដូច្នេះ នៅខែឧសភា ឆ្នាំ២០២៦ ភាគីទាំងពីរបានជម្រាបជូន CAO ថា ពួកគេអាចដោះស្រាយពាក្យបណ្តឹងបាន តាមរយៈការចរចាដោយផ្ទាល់ ហើយបានស្នើសុំឱ្យ CAO បិទសំណុំរឿងនេះ។

[5] គោលនយោបាយ CAO (កថាខណ្ឌ ៥៥) ចែងថា "ប្រសិនបើភាគីនានាយល់ព្រម ពួកគេអាចចូលរួមដោយផ្ទាល់ជាមួយគ្នាទៅវិញទៅមកក្នុងអំឡុងពេលដំណើរការវាយតម្លៃ ដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង។ [...] ក្នុងករណីដែលបញ្ហានៅក្នុងពាក្យបណ្តឹងត្រូវបានដោះស្រាយ ហើយដោយមានការយល់ព្រមពីដើមបណ្តឹង CAO នឹងចេញរបាយការណ៍វាយតម្លៃ និងសេចក្តីសន្និដ្ឋាន ដើម្បីបិទសំណុំរឿងនេះ។"

# ឧបសម្ព័ន្ធ ក. ដំណើរការដោះស្រាយពាក្យបណ្តឹងរបស់ CAO



ដោយអនុលោមតាមគោលនយោបាយយន្តការគណនេយ្យភាពឯករាជ្យ (CAO) របស់ IFC/MIGA ជំហានខាងក្រោមជាធម្មតាត្រូវបានអនុវត្ត ឆ្លើយតបទៅនឹងពាក្យបណ្តឹងដែលបានទទួលៈ

**ជំហានទី១ៈ** ការបញ្ជាក់ថាបានទទួលបានពាក្យបណ្តឹង។

**ជំហានទី២ៈ** ***ភាពទទួលយកបានៈ*** ការកំណត់អំពីភាពទទួលយកបានរបស់ពាក្យបណ្តឹងសម្រាប់ការវាយតម្លៃក្រោមអាណត្តិរបស់ CAO។ដំណើរការនេះត្រូវធ្វើឡើងក្នុងរយៈពេលមិនលើសពី ១៥ ថ្ងៃនៃថ្ងៃធ្វើការ។

**ជំហានទី៣ៈ** ***ការវាយតម្លៃៈ*** CAO វាយតម្លៃលើបញ្ហានានានៅក្នុងពាក្យបណ្តឹង និងជួយភាគីពាក់ព័ន្ធក្នុងការស្វែងយល់ និងកំណត់ ថាតើពួកគេចង់បន្តដំណោះស្រាយដោយព្រមព្រៀងគ្នា តាមរយៈដំណើរការបែបសហការ ដែលកោះប្រជុំដោយមុខងារដោះស្រាយវិវាទរបស់ CAO ឬថាតើពួកគេចង់ឱ្យករណីនេះត្រូវបានចាត់ចែងដោយមុខងារអនុលោមភាពរបស់ CAO រួមទាំងការត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវផ្នែកបរិស្ថាន និងសង្គម របស់ IFC/MIGA។ ដំណើរការនេះអាចចំណាយពេលរហូតដល់អតិបរមា ៩០ ថ្ងៃនៃថ្ងៃធ្វើការ ដោយមានលទ្ធភាពពន្យារពេលអតិបរមា ៣០ ថ្ងៃនៃថ្ងៃធ្វើការបន្ថែម ប្រសិនបើបន្ទាប់ពីរយៈពេល ៩០ ថ្ងៃនៃថ្ងៃធ្វើការ (១) ភាគីទាំងពីរបញ្ជាក់ថា ដំណោះស្រាយលើពាក្យបណ្តឹង ទំនងជានឹងអាចកើតមាន ឬ (២) ភាគីណាមួយបង្ហាញចំណាប់អារម្មណ៍ក្នុងការដោះស្រាយវិវាទ ហើយភាគីម្ខាងទៀតអាចនឹងយល់ព្រម។

**ជំហានទី៤ៈ** ***ការសម្របសម្រួលការដោះស្រាយវិវាទៈ*** ប្រសិនបើភាគីទាំងពីរជ្រើសរើសបន្តដំណើរការសហការមុខងារដោះស្រាយវិវាទរបស់ CAO នឹងត្រូវចាប់ផ្តើម។ ដំណើរការនេះជាធម្មតា គឺផ្អែកលើ ឬផ្តើមឡើងដោយអនុស្សរណៈនៃការយោគយល់គ្នា និង/ឬបទបញ្ជាផ្ទៃក្នុងដែលបានព្រមព្រៀងគ្នាទៅវិញទៅមក រវាងភាគីទាំងពីរ។ ក្នុងដំណើរការនេះ អាចមានការសម្របសម្រួល/ការសម្រុះសម្រួល ការស្វែងរកការពិតរួមគ្នា ឬវិធីសាស្ត្រដោះស្រាយផ្សេងទៀតដែលបានព្រមព្រៀងគ្នា ដែលនាំទៅរកកិច្ចព្រមព្រៀងសះជា ឬគោលដៅសមស្របផ្សេងទៀត ដែលបានព្រមព្រៀងគ្នាទៅវិញទៅមក។ គោលបំណងចម្បងនៃវិធីសាស្ត្រដោះស្រាយបញ្ហាប្រភេទនេះ គឺដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង និងបញ្ហាសំខាន់ៗផ្សេងទៀត ដែលពាក់ព័ន្ធនឹងពាក្យបណ្តឹង ដែលត្រូវបានកំណត់ក្នុងអំឡុងពេលវាយតម្លៃ ឬដំណើរការដោះស្រាយវិវាទ តាមរបៀបមួយដែលភាគីរងផលប៉ះពាល់អាចទទួលយកបាន។

ឬ

***ការពិនិត្យវាយតម្លៃ និងការស៊ើបអង្កេតអនុលោមភាពៈ*** ពាក្យបណ្តឹងត្រូវបានផ្ទេរទៅមុខងារអនុលោមភាពរបស់ CAO ប្រសិនបើភាគីនានាជ្រើសរើសយកដំណើរការស៊ើបអង្កេត ឬប្រសិនបើដំណើរការដោះ

ស្រាយវិវាទ បង្កើតឱ្យមានកិច្ចព្រមព្រៀងមួយផ្នែក ឬមិនមានកិច្ចព្រមព្រៀងទាល់តែសោះ។ សមាជិកសហគមន៍រងផលប៉ះពាល់យ៉ាងហោចណាស់ម្នាក់ ត្រូវតែផ្តល់ការយល់ព្រមច្បាស់លាស់សម្រាប់ការផ្ទេរនេះ លើកលែងតែ CAO បានដឹងអំពីការបារម្ភស្តីពីការគំរាមកំហែង និងការសងសឹក។ មុខងារអនុលោមភាពរបស់ CAO ត្រួតពិនិត្យលើអនុលោមភាពរបស់ IFC/MIGA ជាមួយនឹងគោលនយោបាយបរិស្ថាន និងសង្គម វាយតម្លៃគ្រោះថ្នាក់ដែលពាក់ព័ន្ធ និងផ្តល់អនុសាសន៍អំពីសកម្មភាពកែតម្រូវសមស្របណាមួយ។ ទីមួយ ការវាយតម្លៃអនុលោមភាព កំណត់ថាតើត្រូវមានការស៊ើបអង្កេតបន្ថែមដែរឬទេ ដែលការវាយតម្លៃនេះអាចចំណាយពេលរហូតដល់ ៤៥ ថ្ងៃនៃថ្ងៃធ្វើការ ដោយអាចពន្យារពេល ២០ ថ្ងៃនៃថ្ងៃធ្វើការ ក្នុងកាលៈទេសៈពិសេស។ ប្រសិនបើត្រូវមានការស៊ើបអង្កេត បន្ទាប់ពីការវាយតម្លៃរួច នឹងមានការស៊ើបអង្កេតលើអនុលោមភាពស៊ីជម្រៅ លើការអនុវត្តរបស់ IFC/MIGA។ របាយការណ៍ស៊ើបអង្កេតមួយនឹងត្រូវបានផ្សព្វផ្សាយជាសាធារណៈ រួមជាមួយនឹងការឆ្លើយតបរបស់ IFC/MIGA និងផែនការសកម្មភាពមួយ ដើម្បីកែតម្រូវការរកឃើញអំពីការមិនអនុលោម និងគ្រោះថ្នាក់ដែលពាក់ព័ន្ធ។

**ជំហានទី៥៖ ការពិនិត្យ និងការតាមដាន។** ក្នុងករណីរកឃើញការមិនអនុលោម និងគ្រោះថ្នាក់ពាក់ព័ន្ធ CAO នឹងតាមដានលើការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃផែនការសកម្មភាពនោះ។